# ព្រះរាជក្រម

នស/រកម/១២០៦/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីភាតព្វកិច្ចយោធា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី ២៥ ខែតុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ភាតរូកិច្ចយោធា

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ច្បាប់នេះមានគោលដៅកំណត់បែបបទការអនុវត្តកាតព្វកិច្ច រួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ដូចមានចែងក្នុងមាត្រា ៤៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

កាតព្វកិច្ចយោធា ជាករណីយកិច្ចចាំបាច់ និងជាកិត្តិយសដ៏ឧត្តុង្គឧត្តមរបស់ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ។

កាតព្វកិច្ចយោធា ជាមូលដ្ឋានគ្រឹះនៃប្រភពកសាងកម្លាំងសម្រាប់វិស័យការពារជាតិ និងការអភិវឌ្ឍន៍កាយសម្បទា ដែលជាតម្រូវការរបស់ប្រទេសជាតិ ។

**មាត្រា ២ .-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបទាំងពីរភេទ ដែលមានអាយុពី ១៨ ដល់ ៣០ឆ្នាំ ត្រូវបំពេញកាតព្វកិច្ចយោធា តាមការកំណត់នៃច្បាប់នេះ ។

ការបំពេញកាតព្វកិច្ចយោធារបស់ប្រជាពលរដ្ឋខ្មែរជាស្ត្រីភេទគ្រប់រូប ត្រូវផ្អែកតាមការស្ម័គ្រចិត្ត ។

ប្រជាពលរដ្ឋខ្មែរ ដែលមានសញ្ជាតិពីរ ហើយដែលរស់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញកាតព្វកិច្ចយោធាក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ .-**

ចំនួនប្រជាពលរដ្ឋ និងលក្ខខណ្ឌទាំងឡាយក្នុងការចូលបំពេញកាតព្វកិច្ចយោធាសម្រាប់វគ្គនីមួយៗ រៀងរាល់ឆ្នាំ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងការពារជាតិ ។

# ជំពូកទី ២
# រយៈពេលចូលបំពេញកាតព្វកិច្ចយោធា
# និងក្របខ័ណ្ឌយោធិនបម្រុង

**មាត្រា ៤ .-**

ការបំពេញកាតព្វកិច្ចយោធា មានកំណត់ពេល ១៨ ខែ គិតពីថ្ងៃចូលបំពេញកាតព្វ-កិច្ច ។

**មាត្រា ៥ .-**

យោធិនដែលបានបញ្ចប់កាតព្វកិច្ចយោធាហើយ ត្រូវអនុញ្ញាតឱ្យទៅកាន់ជីវភាពស៊ីវិលវិញ ប៉ុន្តែត្រូវឋិតក្នុងក្របខ័ណ្ឌយោធិនបម្រុង ។ យោធិននេះ ក៏អាចស្ថិតនៅក្នុងអាជីពយោធាបន្តទៅទៀតបាន ទៅតាមតម្រូវការរបស់ក្រសួងការពារជាតិ និងដោយឈរលើមូលដ្ឋានស្ម័គ្រចិត្ត ។

ក្នុងស្ថានភាពជាយោធិនបម្រុងនេះ សាមីជនត្រូវបានទទួលការអញ្ជើញគ្រប់ពេលវេលាមកបំពេញភារកិច្ច តាមការចាំបាច់របស់ប្រទេសជាតិ ក្នុងកងទ័ពតាមគ្រប់រូបភាពតាមកាលៈទេសៈតម្រូវ ។

**មាត្រា ៦ .-**

លក្ខន្តិកៈដោយឡែកនៃយោធិនបម្រុង ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

# ជំពូកទី ៣
# ការចុះបញ្ជី ការអញ្ជើញ ការពន្យារពេល
# និងការអនុញ្ញាតឱ្យរួចផុតពីកាតព្វកិច្ចយោធា

## មាត្រា ៧.-

ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលដល់អាយុត្រូវបំពេញកាតព្វកិច្ចយោធាត្រូវអញ្ជើញទៅចុះឈ្មោះក្នុងបញ្ជីជំរឿនកាតព្វកិច្ចយោធា ។

ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីតម្រូវឱ្យចូលបំពេញកាតព្វកិច្ចយោធា ត្រូវទទួលបាននូវការជូនដំណឹងអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការចុះឈ្មោះចូលបំពេញកាតព្វកិច្ចយោធា ។

ការអញ្ជើញទៅចុះឈ្មោះ និងការចូលបំពេញកាតព្វកិច្ចយោធាត្រូវធ្វើឡើងតាមរយៈអាជ្ញាធរដែនដី ។

លក្ខខណ្ឌ និងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញនិងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៨.-

ការពន្យារពេលនៃការអញ្ជើញមកបំពេញកាតព្វកិច្ចយោធា ត្រូវអនុវត្តតាមករណីដូចខាងក្រោម :

ប្រជាពលរដ្ឋដែលកំពុងជាប់បំពេញការងារជំនាញក្នុងសហគ្រាសសាធារណៈ ឬ ឯកជនអាចដាក់ពាក្យសុំពន្យារពេលមួយឆ្នាំម្តងៗ ប៉ុន្តែការសុំពន្យារពេលនេះមិនអាចលើសពី ៣ ឆ្នាំឡើយ

-ប្រជាពលរដ្ឋជាប់ពាក់ព័ន្ធបទល្មើស ដែលកំពុងស្ថិតក្នុងសមត្ថកិច្ចតុលាការ

-ប្រជាពលរដ្ឋជាប់ពាក់ព័ន្ធក្នុងរឿងព្រហ្មទណ្ឌដែលសមត្ថកិច្ចកំពុងតាមដាន ។

លក្ខខណ្ឌពន្យារពេលនៃការអញ្ជើញមកបំពេញកាតព្វកិច្ចយោធានៃយុវជនកំពុងជាប់ការសិក្សា និងប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេសត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៩.-**

ការអនុញ្ញាតឱ្យរួចផុតពីកាតព្វកិច្ចយោធាត្រូវអនុវត្តចំពោះ :

-ប្រជាពលរដ្ឋដែលបានបញ្ចប់សេវាជាយោធិនជាប់កិច្ចសន្យា

-អ្នកឯកទេសជំនាញ ដែលបានចុះកិច្ចសហប្រតិបត្តិការបំពេញបេសកកម្មស្រាវជ្រាវ ឬ អនុវត្តផ្ទាល់នូវកិច្ចការដែលជាប្រយោជន៍ផ្នែកសាធារណៈនៃកងយោធពលខេមរភូមិន្ទ ដែលមានរយៈពេលស្មើនឹងស្ថានភាពកាតព្វកិច្ចយោធាចំនួន ១៨ ខែ

-ព្រះសង្ឃ បព្វជិត នៃសាសនាផ្សេងៗ ដែលមានការទទួលស្គាល់ពីក្រសួងធម្មការ និងកិច្ចការសាសនា

-ប្រជាពលរដ្ឋដែលមានកាយសម្បទាមិនគ្រប់គ្រាន់តាមការតម្រូវ ដោយមានការត្រួតពិនិត្យជាក់ស្តែងពីគណៈកម្មការសុខាភិបាលនៅនឹងកន្លែងចំពោះមុខសាធារណជនក្នុងមូលដ្ឋានដែលមានធ្វើការជ្រើសរើស ។

## ជំពូកទី ៤

## អំពីអត្ថប្រយោជន៍នៃការបំពេញកាតព្វកិច្ចយោធា

**មាត្រា ១០.-**

ក្នុងរយៈពេលនៃការបំពេញកាតព្វកិច្ចយោធា យោធិនគ្រប់រូបត្រូវទទួលប្រាក់បំណាច់ និងការឧបត្ថម្ភផ្សេងៗ សម្រាប់ជីវភាពប្រចាំថ្ងៃតាមការកំណត់របស់ក្រសួងការពារជាតិ ។

**មាត្រា ១១.-**

យោធិនទាំងពីរភេទ ដែលបានបង្កើតស្នាដៃល្អក្នុងពេលបំពេញកាតព្វកិច្ចយោធាត្រូវបានជូនរង្វាន់ និង លើកសរសើរដូចយោធិនអាជីព ហើយក្នុងករណីមានជំងឺ របួស

ឬ គ្រោះថ្នាក់ផ្សេងៗត្រូវទទួលការសង្គ្រោះ ព្យាបាល ថែរក្សា និងការសរសើរលើកទឹកចិត្ត ពីក្រសួងការពារជាតិ ។

ក្នុងករណីពលី មរណៈ ឬ ពិការ ដោយសារបុព្វហេតុប្រទេសជាតិ ក្នុងអំឡុងពេល បំពេញកាតព្វកិច្ចយោធា ក្រសួងការពារជាតិត្រូវផ្តល់ការឧបត្ថម្ភជារបបតាមគោលការណ៍ ដូចយោធិនអាជីពដែរ ។

**មាត្រា ១២.-**

យោធិនទាំងពីរភេទ ដែលបានបញ្ចប់កាតព្វកិច្ចយោធា :

-មានសិទ្ធិបន្តការសិក្សាតាមគ្រឹះស្ថានសិក្សាដើមរបស់ខ្លួនវិញ

-មានអាទិភាពទទួលបានការបណ្តុះបណ្តាលមុខវិជ្ជាជីវៈ

-មានអាទិភាពក្នុងការប្រឡងប្រជែង ឬ ជ្រើសរើសចូលបម្រើក្នុងស្ថាប័នរដ្ឋ អង្គការ សហគ្រាស សាធារណៈ ឬ ក្រុមហ៊ុនឯកជននានា ។

ស្ថាប័នរដ្ឋ អង្គការ និងក្រុមហ៊ុនឯកជននានា ត្រូវទទួលឱ្យប្រជាពលរដ្ឋដែលបាន បញ្ចប់កាតព្វកិច្ចយោធានោះ ចូលបម្រើការងារវិញក្នុងក្របខ័ណ្ឌដើមដោយរក្សាឋានៈដូច មុនពេលទៅបំពេញកាតព្វកិច្ចយោធា ហើយផ្តល់អាទិភាពក្នុងការពិចារណាតម្លើងឋានៈ ឬ ឋានន្តរសក្តិ ។ រយៈពេលបំពេញកាតព្វកិច្ចយោធា ត្រូវបានរាប់បញ្ចូលក្នុងអតីតភាព សម្រាប់ការចូលនិវត្តន៍របស់សាមីជនផងដែរ ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ១៣.-**

ប្រជាពលរដ្ឋគ្រប់រូប ដែលត្រូវអញ្ជើញឱ្យចូលបំពេញកាតព្វកិច្ចយោធា ហើយ

មិនបានមកបង្ហាញខ្លួនតាមការអញ្ជើញក្នុងរយៈពេល ៣០ ថ្ងៃ គិតពីថ្ងៃទទួលដំណឹងត្រូវចាត់ទុកជាជនរឹងរូស លើកលែងតែមានមូលហេតុត្រឹមត្រូវពុំអាចមកបង្ហាញខ្លួនបាន ។

ជនដែលរឹងរូស និងជនរួមគំនិតក្នុងការគេចវេះពីកាតព្វកិច្ចយោធា :

-ក្នុងកាលៈទេសៈប្រទេសមានសន្តិភាព ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ ១ ឆ្នាំ ។

-ក្នុងកាលៈទេសៈប្រទេសមានសង្គ្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ ។

ក្នុងករណីជនល្មើសទទួលកំហុសរបស់ខ្លួន ហើយសុខចិត្តចូលមកបំពេញកាតព្វកិច្ចយោធាវិញនោះ ជននោះត្រូវបានទទួលការអនុគ្រោះ ប៉ុន្តែត្រូវបញ្ជូនទៅបំពេញការងារក្នុងអង្គភាពវិន័យ ។

**មាត្រា១៤.-**

ជនណាដែលធ្វើឱ្យពិការដល់ខ្លួន ឬ រត់ទៅនៅបរទេសដើម្បីគេចវេះពីកាតព្វកិច្ចយោធា :

-ក្នុងកាលៈទេសៈប្រទេសមានសន្តិភាព ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ ខែ ដល់ ២ ឆ្នាំ ។

-ក្នុងកាលៈទេសៈប្រទេសមានសង្គ្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ដល់ ៥ ឆ្នាំ ។

**មាត្រា១៥.-**

ជនណាដែលឆ្លៀតយកឋានៈតួនាទី ដើម្បីរាំងស្ទះមិនឱ្យពលរដ្ឋចូលបំពេញកាតព្វ-កិច្ចយោធា ឬប្រើប្រាស់ច្បាប់នេះ ធ្វើអាជីវកម្មដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ដល់ ៥ឆ្នាំ ។

ﺉ

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០៦
ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រ/ល.០៦១២.៥៣៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា
ទៀ បាញ់

លេខ: ៤៨៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ ធ្នូ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ [illegible]